ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sports

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ROYAL UNIVERSITY OF LAW AND ECONOMICS

មហាវិទ្យាល័យ នីតិសាស្ត្រ

Faculty of law

# កិច្ចការស្រាវជ្រាវ

មុខវិជ្ជា: **ម៉ោងអនុវត្តរដ្ឋប្បវេណី**

**(TD Civil law)**

ប្រធានបទ:

**ការលែងលះ**

ណែនាំដោយ:

**សាស្ត្រាចារ្យ: ប៊ុន សេង**

ស្រាវជ្រាវដោយ:

ឡេា ក្រឹម

ឆ្នាំទី២ (២០១១-២០១២)

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sports
សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
ROYAL UNIVERSITY OF LAW AND ECONOMICS
មហាវិទ្យាល័យ នីតិសាស្ត្រ
Faculty of law

# កិច្ចការស្រាវជ្រាវ

*មុខវិជ្ជា:* **ម៉ោងអនុវត្តរដ្ឋប្បវេណី**

(TD Civil law)

*ប្រធានបទ:*

## ការលែងលះ

*ណែនាំដោយ:*

**សាស្ត្រាចារ្យ: ប៊ុន សេង**

*ស្រាវជ្រាវដោយ:*

ឡៅ ក្រឹម

ឆ្នាំទី២ (២០១១-២០១២)

# មាតិកា

ចំណងជើង ទំព័រ

## សេចក្តីផ្តើម


១.ភាគីនៃបណ្តឹងមានចំណងអាពាហ៍ពិពាហ៍ ........ ២

២.អង្គហេតុជាមូលហេតុនៃការលែងលះ ........ ២

៣.នីតិវិធីនៃការលែងលះគ្នា ........ ៣

៤.ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួមរបស់សហព័ន្ធ ........ ៤

 ៤.១.ទ្រព្យសម្បត្តិដោយឡែករបស់សហព័ន្ធម្នាក់ៗ ........ ៤

 ៤.២.ទ្រព្យសម្បត្តិរួមរបស់សហព័ន្ធ ........ ៤

៥.ការទាមទារបែងចែកទ្រព្យសម្បត្តិ ........ ៥

 ៥.១.ការបែងចែកទ្រព្យសម្បត្តិតាមការពិភាក្សា ........ ៥

 ៥.២.ការបែងចែកទ្រព្យសម្បត្តិរួមតាមច្បាប់ ........ ៥

៦.ការទាមទារអំណាចមេបាលើកូន ........ ៦

៧. សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ........ ៧


## សេចក្តីសន្និដ្ឋាន


ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

ជាការពិតណាស់អាពាហ៍ពិពាហ៍ គឺកិច្ចសន្យាឱឡារិកធ្វើឡើងដោយគោលការណ៍ស្ម័គ្រចិត្ត និងមានចំណងតាមផ្លូវច្បាប់ ហើយបុរសនិងនារី ដែលជាសហព័ន្ធមិនអាចទាមទារលែងលះតាមទំនើងចិត្តរបស់ខ្លួនឡើយ។ ការរស់នៅក្នុងមួយជីវិតរបស់មនុស្សម្នាក់ៗ តែងតែប្រាថ្នាចង់រៀបអាពាហ៍ពាហ៍មួយសមប្រកបដោយសុភមង្គលនៅក្នុងគ្រួសារ ប៉ុន្តែក្តីប្រាថ្នានោះមិនសុទ្ធតែបានសម្រេចតាមការប៉ងប្រាថ្នាទាំងអស់នោះទេ អ្នកខ្លះមានសុភមង្គលរហូតដល់ចាស់ទុំរហូតដល់លុះលុងអវសាននៃជីវិត ប៉ុន្តែខ្លះទៀតក៏មានការខ្វែងគំនិតទាស់ទែងគ្នារហូតឈានទៅដល់ការលែងលះក៏មាន ។ ទន្ទឹមនឹងនេះក៏អាចបណ្តាលមកពីកត្តាជាច្រើន ដែលបណ្តាលអោយភាគីទាំងសងខាងមិនរស់នៅចុះសម្រុងនឹងគ្នាពោលគឺ ភាគីនីមួយៗយល់ឃើញថា ទំនាក់ទំនងរវាងប្តី-ប្រពន្ធរបស់ពួកគេត្រូវតែបែកគ្នា។

ហេតុនេះបានជាក្រសួងយុត្តិធម៌ សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) បានបង្កើតឡើងនូវក្រមរដ្ឋប្បវេណី ដែលប្រកាសអោយប្រើនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសអោយប្រើនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦។ ម្យ៉ាងវិញទៀតនៅក្នុងក្រមទាំងពីរនេះ ក៏បានបញ្ជាក់អំពីការលែងលះរវាងប្តី-ប្រពន្ធផងដែរ។

តើបណ្តាលមកពីមូលហេតុអ្វីខ្លះដែលធ្វើអោយមានការលែងលះ ហើយវាផ្តល់ផលប៉ះពាល់អ្វីខ្លះដល់គ្រួសារ និងសង្គមជាតិ?

## ១.ភាគីនៃបណ្តឹងមានចំណងអាពាហ៍ពិពាហ៍

ការលែងលះអាចធ្វើបានលុះត្រាតែភាគីនៃបណ្តឹង គឺជាសហព័ន្ធដែលមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដែលអ្នកទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅមុខមន្ត្រីអត្រានុកូលដ្ឋាន(មាត្រា ៩៥៥)។ ដូច្នេះ ភាគីដែលដាក់ពាក្យបណ្តឹងត្រូវតែភ្ជាប់នូវសំបុត្រអាពាហ៍ពិពាហ៍ជាមួយផង វៀរលែងតែដោយហេតុណាផ្សេង ដែលភាគីនោះមិនអាចនឹងមានលទ្ធភាពផ្តល់អោយបាន។

ម្យ៉ាងវិញទៀត ភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបានក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា។

## ២.អង្គហេតុជាមូលហេតុនៃការលែងលះ

ជាការពិតណាស់ការរៀបអាពាហ៍ពិពាហ៍ គឺធ្វើឡើងដោយគោលការណ៍ស្ម័គ្រចិត្ត និងនៅពេលមានចំណងតាមផ្លូវច្បាប់ ហើយបុរសនិងនារី ដែលជាសហព័ន្ធមិនអាចទាមទារលែងលះតាមទំនើងចិត្តរបស់ខ្លួនឡើយ។ ដូច្នេះ ភាគីណាមួយដែលជាប្តី ឬប្រពន្ធត្រូវតែមានអង្គហេតុបញ្ជាក់ពីមូលហេតុរបស់ខ្លួនដែលបណ្តាលអោយខ្លួនមិនអាចនឹងរួមរស់ជាមួយសហព័ន្ធទៅទៀតបាន ហើយចំណុចនេះក៏ជាវិធានមួយក្នុងការការពារភាពសុចរិតរបស់ភាគីម្ខាងទៀតដែរ។ ផ្ទុយទៅវិញ តុលាការក៏អាចច្រានចោលការទាមទារលែងលះនេះបានដែរក្នុងករណីខ្លះ។

មូលហេតុនៃការលែងលះគ្នានេះមានបញ្ញត្តិនៅក្នុងមាត្រា ៩៧៨ កថាខ័ណ្ឌទី១ រួមមាន:

ក. បើបានប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ន្ធ

ខ. បើបានបោះបង់សហព័ន្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ

គ. បើមិនដឹងច្បាស់ថាសហព័ន្ធស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ

ឃ. បើសហព័ន្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍

ង. បើទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ឬករណីផ្សេងទៀតដែលគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។

ទោះបីជាមានមូលហេតុដូចបានរៀបរាប់ខាងលើក៏ដោយ ករណីខ្លះការលែងលះគ្នាអាចបណ្តាលអោយការទ្រទ្រង់ជីវភាពរបស់សហព័ន្ធ ឬកូនក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់ដែលពុំអាចទ្រាំបាន តុលាការអាចនឹងពិចារណា អំពីបញ្ហាអស់ទាំងនេះក្នុងការធ្វើសេចក្តីសម្រេចច្រានចោលការទាមទារ

លែងលះបាន។ បញ្ហានេះ អាចមានមូលហេតុដូចដែលដើមបណ្តឹងបានលើកឡើងក៏ពិតមែន ប៉ុន្តែហេតុផលនាំអោយកើតមានយ៉ាងដូច្នេះ ក៏អាចជាដើមហេតុបានកើតចេញពីសហព័ន្ធជាដើមបណ្តឹងបង្ករឡើងផងដែរ។ ចំណងអាពាហ៍ពិពាហ៍នៅតែមានការទទួលខុសត្រូវដោយសាមគ្គីរបស់សហព័ន្ធ ចំពោះកាតព្វកិច្ចក៏នៅតែមានដែរ(មាត្រា ៩៧៥ចំណុច **ក**) ដូច្នេះ ដើម្បីសង្គ្រោះដល់សហព័ន្ធម្ខាងទៀត ព្រមទាំងកូនរបស់សហព័ន្ធផងនោះ តុលាការចាំបាច់ត្រូវពិចារណាអោយបានល្អិតល្អន់ក្នុងការសម្រេចចោលការទាមទារ (មាត្រា ៩៧៨ កថាខ័ណ្ឌទី២)។ មានករណីខ្លះសហព័ន្ធម្ខាង ដែលដើមបណ្តឹងទាមទារការលែងលះដូចមានកំណត់ក្នុងចំណុច **ឃ** និង **ង** ខាងលើក៏ដោយ ប៉ុន្តែបើដើមបណ្តឹងនោះបានទាមទារលែងលះដោយផ្ទុយនឹងភាពសុចរិត ធ្វេសប្រហែលយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិការ និងជួយសង្គ្រោះចំពោះសហព័ន្ធ តុលាការអាចច្រានចោលការទាមទាលែងលះគ្នានោះដោយឆន្ទានុសិទ្ធិបាន(មាតា ៩៧៨ កថាខ័ណ្ឌទី៣)។

ក្រៅពីមូលហេតុនៃការលែងលះដូចបានរៀបរាប់ខាងលើ សហព័ន្ធទាំងពីរអាចលែងលះគ្នាបានតាមរយៈការព្រមព្រៀងគ្នា។ ករណីនេះ តុលាការមិនត្រូវគិតពីមូលហេតុដែលនាំអោយមានការលែងលះឡើយ ប៉ុន្តែតុលាការត្រូវយល់ច្បាស់ថា ការព្រមព្រៀងនេះ គឺជាគោលបំណងពិតប្រាកដរបស់ភាគីទាំងសងខាង (មាត្រា ៩៧៩)។

## ៣.នីតិវិធីនៃការលែងលះគ្នា

ភាគីណាមួយដែលជាសហព័ន្ធ ប្តី ឬប្រពន្ធ មានពិតប្រាកដក្នុងការលែងលះគ្នា ដោយផ្អែកលើមូលហេតុត្រឹមត្រូវ អាចដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច ដោយយោងតាមបញ្ញត្តិមាត្រា ១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និងរឿងក្តីអំពីបុគ្គលភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន (មាត្រា ៩៨២ កថាខ័ណ្ឌទី២)។

ក្រៅពីភាគីដែលអាចដាក់ពាក្យសុំលែងលះគ្នាទៅក្រុមប្រឹក្សាឃុំ/សង្កាត់ ខាងលំនៅឋាន ឬទីសំណាក់ ដូចបានកំណត់ក្នុងកថាខ័ណ្ឌទី១ និង៣ នៃមាត្រា ១០បាន។ ក្នុងករណីនេះ ក្រុមប្រឹក្សា ឃុំ/សង្កាត់ អាចធ្វើការបញ្ចុះបញ្ចូលអោយសះជាគ្នាបានទេ ក្នុងអំឡុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ។ បើមិនអាចបញ្ចុះបញ្ចូលអោយសះជាគ្នាបានទេ ត្រូវចាត់ទុកថាមានពាក្យ បណ្តឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅតុលាការជាបន្ទាន់(មាត្រា៩៨២ កថាខ័ណ្ឌទី២)។ ក្នុងករណីចាំបាច់អាចចេញដីការសម្រេចបង្គាប់អោយធ្វើការចាត់ចែងរក្សាការពារ ចំពោះការបំបែកលំនៅ ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ អាហារកិច្ចរបស់សហព័ន្ធបន្ទុកនៃ

សោហ៊ុយអាពាហ៍ពិពាហ៍ និងសោហ៊ុយចិញ្ចឹមបីបាច់កូនជាអាទិ៍ តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិបាន (មាត្រា ៩៨៣)។

បើទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាដ៏ដោយ ក៏តុលាការអាចសាកល្បងធ្វើការផ្សះផ្សាម្តងទៀតបាន។ ប៉ុន្តែបើការផ្សះផ្សានោះពុំអាចសម្រេចបានទេនោះ តុលាការត្រូវយកបណ្តឹងលែងលះគ្នាមកធ្វើការវិនិច្ឆ័យទៅតាមនីតិវិធី ហើយធ្វើការបកស្រាយប្រកាសសាលក្រម។

## ៤.ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួមរបស់សហព័ន្ធ

ជាទូទៅនៅពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានកាត់ផ្តាច់ ជម្លោះនៃការបែងចែកទ្រព្យសម្បត្តិរវាងសហព័ន្ធទាំងពីរក៏កើតមានឡើង។ ដូច្នេះ តុលាការត្រូវកំណត់ថាអ្វីជាទ្រព្យសម្បត្តិដោយឡែក និងអ្វីជាទ្រព្យរួមរបស់សហព័ន្ធជាមុន។

### ៤.១.ទ្រព្យសម្បត្តិដោយឡែករបស់សហព័ន្ធម្នាក់ៗ

ទ្រព្យសម្បត្តិដោយឡែករបស់សហព័ន្ធណាម្នាក់គឺ:

ក. ទ្រព្យសម្បត្តិ ដែលសហព័ន្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍

ខ. ទ្រព្យសម្បត្តិ ដែលសហព័ន្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

឵ឃ. ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងចំណុច **ក** និង **ខ** ខាងលើ។ ទ្រព្យសម្បត្តិ នៅក្នុងចំណុចនេះមានន័យថា ជាការប្តូររូបវត្ថុនៃទ្រព្យសម្បត្តិដោយឡែក ដែលមាននៅក្នុងចំណុច **ក** និង **ខ** ដោយការចាត់ចែង ដូចជា លក់ ដូរ... ជាដើម ប៉ុន្តែ ត្រូវមានអង្គហេតុនេះច្បាស់លាស់(មាត្រា ៩៧២)។

នៅមុនពេលភាគីទាំងសងខាងចុះសំបុត្រអាពាហ៍ពិពាហ៍ ប្រសិនបើភាគីទាំងពីរបានពិភាក្សា ឬធ្វើកិច្ចសន្យាជាមួយគ្នា អំពីការដាក់ទ្រព្យសម្បត្តិដោយឡែកបញ្ចូលជាទ្រព្យសម្បត្តិរួមនោះមានន័យថា ពុំមានទ្រព្យសម្បត្តិដោយឡែករបស់សហព័ន្ធណាម្នាក់ទៀតឡើយ ពោលគឺវាជាទ្រព្យសម្បត្តិរួមទាំងអស់ចាប់តាំងពីមានចំណងអាពាហ៍ពិពាហ៍មក។

### ៤.២.ទ្រព្យសម្បត្តិរួមរបស់សហព័ន្ធ

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយណាដែលសហព័ន្ធទាំងសងខាង ឬមានតែម្ខាងទទួលបាននៅក្នុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលសហព័ន្ធមាននៅមុនពេលរៀបអាពាហ៍

ពិពាហ៍ និងទ្រព្យសម្បត្តិដែលសហព័ន្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន ក្នុងដែលចំណង អាពាហ៍ពិពាហ៍មិនកាត់ផ្តាច់(មាត្រា ៩៧៣)។

## ៥.ការទាមទារបែងចែកទ្រព្យសម្បត្តិ

ជាទូទៅ រាល់ពាក្យបណ្តឹងនៃការលែងលះគ្នាសហព័ន្ធនីមួយៗតែងតែមានការទាមទារបែងចែកទ្រព្យសម្បត្តិ ដែលមានចាប់តាំងពីមានចំណងអាពាហ៍ពិពាហ៍ ហើយការបែងចែកនោះចែកចេញជា **ពីរ** ប្រភេទគឺ:

### ៥.១.ការបែងចែកទ្រព្យសម្បត្តិតាមការពិភាក្សា

បើមានការទាមទារទ្រព្យសម្បត្តិ ភាគីទាំងពីរអាចពិភាក្សាគ្នាអំពីការបែងចែកទ្រព្យសម្បត្តិដោយឆន្ទៈព្រមព្រៀងរបស់ភាគីទាំងពីរបាន ហើយក្នុងករណីនេះទោះបីជាទ្រព្យសម្បត្តិដោយឡែក ឬជាទ្រព្យសម្បត្តិរួមក៏ដោយ បើមានការលះបង់ ឬការផ្តល់សម្បទានរវាងគ្នានិងគ្នាក្នុងការបែងចែក តុលាការត្រូវធ្វើការបែងចែកទៅតាមការព្រមព្រៀងនោះ។ ប្រការដែលសំខាន់ គឺការព្រមព្រៀងនោះត្រូវកើតចេញពីឆន្ទៈដោយសេរីពិតប្រាកដរបស់ភាគីទាំងពីរ(មាត្រា ៩៨០ កថាខ័ណ្ឌទី១)។

លើសពីនេះទៅទៀត ក្នុងករណីនៃការបែងចែកទ្រព្យដោយកិច្ចពិភាក្សាគ្នានេះ មានពេលខ្លះវាជាការលាក់ទុកនូវទ្រព្យសម្បត្តិពិតប្រាកដ ដែលអាចមានជាឧទាហរណ៍: ដូចជាបើប្តីលែងលះប្រពន្ធ ហើយចែកទ្រព្យគ្នាដើម្បីគោលបំណងរត់គេចពីការដេញដោលពីសំណាក់ម្ចាស់បំណុល។ ដូច្នេះ បើចំនួនទឹកប្រាក់នៃចំណែកទ្រព្យសម្បត្តិមានច្រើនហួសហេតុ ខុសពីខ្លឹមសារដែលមានចែងក្នុងមាត្រា ៩៧៥ ចំណុច **ខ** ហើយបើសិនជាមានព្រឹត្តិការណ៍ពិសេស ដែលនាំអោយមានការយល់ឃើញថាមានការចែកទ្រព្យនេះគឺជាវិធីចាត់ចែងទ្រព្យដោយបន្លំគេអាចចាត់ទុកចំនួនទាំងអស់ ឬមួយផ្នែកនៃទ្រព្យនោះថាជាកម្មវត្ថុដែលត្រូវលុបចោលដោយអនុវត្តសិទ្ធិលុបចោលអំពើដែលនាំអោយខូចខាតផលប្រយោជន៍។

### ៥.២.ការបែងចែកទ្រព្យសម្បត្តិរួមតាមច្បាប់

កាលបើការពិភាក្សារបស់ភាគីទាំងពីរមិនបានសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិទេ បើភាគីណាមានភស្តុតាងបញ្ជាក់អំពីទ្រព្យសម្បត្តិរួម (មាត្រា ៩៧៣) បើទោះក្នុងចំណោមនោះមានសហព័ន្ធណាម្ខាងបានបំពេញតែការងារគេហកិច្ចក៏ដោយ ក៏ការងារនោះមានតម្លៃស្មើនឹងការងារដែលនៅក្រៅផ្ទះដែរ(មាត្រា ៩៨០ កថាខ័ណ្ឌ៣)។ ដូច្នេះ ទ្រព្យសម្បត្តិរួមត្រូវបែងចែកអោយសហព័ន្ធម្នាក់ៗ ចំនួន ១ ភាគ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម(មាត្រា៩៨០ កថាខ័ណ្ឌទី២ ចំណុច **ខ** វាក្យខ័ណ្ឌទី១)។

លើសពីនេះទៅទៀត តុលាការអាចធ្វើការបែងចែកខុសពីការបែងចែកខាងលើនេះបាន បើសិនមានការទាមទាររបស់ភាគីណាម្ខាង និងក្នុងនោះមានករណីពិសេសដែលត្រូវពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យសម្បត្តិអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍(មាត្រា ៩៨០ កថាខ័ណ្ឌ២ ចំណុច២ វាក្យខ័ណ្ឌ២)។

រាល់ស្ថានភាពពិសេសដូចបានរៀបរាប់ខាងលើ តុលាការត្រូវពិចារណាទៅលើគ្រប់ស្ថានភាពទាំងអស់នៃអង្គហេតុដែលមាន ដើម្បីឈានទៅដល់ការបែងចែកបានត្រឹមត្រូវទៅតាមអត្ថន័យនៃបញ្ញត្តិនេះ។

ដូច្នេះ តុលាការមិនអាចនឹងលើកយកតែស្ថានភាពណាមួយមកពិចារណាដាច់ដោយឡែកដោយមិនគិតពិចារណាដល់ស្ថានភាពពិសេសផ្សេងទៀតទាំងអស់ដែលមាននោះឡើយ។

## ៦.ការទាមទារអំណាចមេបាលើកូន

តាមរយៈគោលការណ៍នៃការសហការប្រើប្រាស់អំណាចមេបា(មាត្រា១០៣៦) ឪពុកម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា។ ប៉ុន្តែបើឪពុក ឬម្តាយណាម្ខាង ពុំអាចប្រើប្រាស់អំណាចមេបាទេ ឪពុក ឬម្តាយម្ខាងទៀតត្រូវប្រើប្រាស់អំណាចមេបានោះ។ បន្ថែមពីនេះ សហព័ន្ធណាដែលមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចត្រូវចិញ្ចឹមបីបាច់ថែរក្សារូបរាងកាយកូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ(មាត្រា១០៣៤)។

នៅក្នុងពាក្យបណ្តឹងនៃការលែងលះ សហព័ន្ធដែលជាដើមបណ្តឹងតែងតែភ្ជាប់ជាមួយនូវការទាមទារបែងចែកទ្រព្យសម្បត្តិ និងការទាមទារអំណាចមេបាលើកូន។ ដូច្នេះ ការសម្រេចអំពីអ្នកមានអំណាចមេបា ក្នុងករណីលែងលះគ្នា និងការទទួលស្គាល់បានកំណត់ដូចខាងក្រោម:

ក. អំណាចមេបាលើកូននេះ តុលាការត្រូវសម្រេចទៅអោយឪពុក ឬម្តាយតាមការពិភាក្សារបស់ភាគី បើសិនណាភាគីទាំងពីរមានឆន្ទៈព្រមព្រៀងគ្នាអំពីការប្រគល់អំណាចមេបានេះ (មាត្រា ១០៣៧ កថាខ័ណ្ឌទី ១)។

ខ. ក្នុងករណីដែលសហព័ន្ធជាឪពុក ឬម្តាយ បានលែងលះគ្នានៅមុនពេលកំណើតកូន ម្តាយ គឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។ ប៉ុន្តែបើនៅក្រោយកំណើតរបស់កូន

ឪពុក/ម្តាយ របស់កូននោះអាចនឹងពិភាក្សាដោយការព្រមព្រៀងគ្នា កំណត់យកឪពុកជាអ្នកមានអំណាចមេបាវិញក៏បាន(មាត្រា ១០៣៧ កថាខ័ណ្ឌទី២)។

ឃ. ផ្ទុយទៅវិញ បើការពិភាក្សានោះមិនបានសម្រេច ឬពុំអាចពិភាក្សាទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបាដោយពិចារណាទៅដល់ផលប្រយោជន៍របស់កូននោះ(មាត្រា ១០៣៧ កថាខ័ណ្ឌទី៣)។

ពាក្យថា "**ផលប្រយោជន៍របស់កូន**" មានន័យថា កូននោះអាចទទួលបាននូវការអប់រំល្អជាការចិញ្ចឹមបីបាច់ថែរក្សាល្អជាង ព្រមទាំងមានស្ថានភាពរស់នៅល្អប្រសើរជាង ពោលគឺបើគិតពីចិត្តសាស្ត្ររបស់ក្មេងនៅពេល ដែលបានរស់នៅដោយផ្ទាល់ជាមួយភាគីណាម្ខាងដែលនឹងត្រូវកំណត់ជាអ្នកមានអំណាចមេបានោះ។

ចំពោះករណីកិច្ចដូចបានរៀបរាប់ខាងលើនេះ តុលាការមិនគួរគប្បីលើកឡើងថា ភាគីណាមួយមានសេដ្ឋកិច្ចធូរធា គឺជាកត្តាកំណត់នៃការផ្តល់អំណាចមេបាអោយទៅភាគីនោះឡើយ ព្រោះបញ្ហាកំណត់អ្នកមានអំណាចមេបានេះនៅមានលក្ខណៈផ្សាភ្ជាប់ទៅនឹងការបែងចែកទ្រព្យសម្បត្តិរួម តាមស្ថានភាពពិសេស(មាត្រា ៩៨០ កថាខ័ណ្ឌទី២ ចំណុច **ខ** )។ ក្រៅពីនេះ កូនក៏មានសិទ្ធិក្នុងការជ្រើសរើសភាគីឪពុក ឬភាគីម្តាយអោយមានអំណាចមេបាលើខ្លួនឯងបានដែរ ក្នុងករណីដែលកូននោះមានអាយុ សមល្មមអាចគិត និងយល់អំពីបញ្ហានេះបាន។ ក្នុងករណីសហព័ន្ធទាំងពីរមានកូនច្រើន តុលាការ ក៏ត្រូវគិតអំពីស្ថានភាពផ្សេងទៀត ដែលទាក់ទងទៅនឹងផលប្រយោជន៍របស់កូននោះដូចជា ការបង្ហាញពីឆន្ទៈរបស់កូនៗនោះផ្ទាល់ អាយុរបស់កូន ឬផលប្រយោជន៍នៃការអោយនៅជុំគ្នា ឬបែកគ្នានៃកូនៗនោះជាដើម។

## ៧. សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

មិនតែប៉ុណ្ណោះការសម្រេចចិត្តអំពីអំណាចមេបា វាទាក់ទងទៅនឹងការផ្តល់សោហ៊ុយចាំបាច់របស់ឪពុក ឬម្តាយ ដែលពុំមានអំណាចមេបា ចំពោះភាគីណាមួយដែលមានអំណាចមេបាលើកូន ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សា(អាហារកិច្ច) កូននោះលុះចម្រើនវ័យជានីតិជន(១៨ឆ្នាំ) ។ ចំពោះការកំណត់អំពីទំហំនៃសោហ៊ុយនោះ តុលាការគប្បីពិចារណាទៅលើគ្រប់ចំណុចទាំងអស់ដូចជា កម្រិតជីវភាពរបស់កូនដែលធ្លាប់មានកន្លងមក តម្រូវការចាំបាច់របស់កូន ព្រមទាំងកម្រិតជីវភាពនៃអ្នកដែលត្រូវទទួលបន្ទុកផ្តល់សោហ៊ុយនោះផងដែរ។ លើសពីនេះ ភាគីដែលមិនបានរស់នៅជាមួយកូន ក៏មានសិទ្ធិជួប និងប្រាស្រ័យទាក់ទងជាមួយកូននោះបានដែរ(មាត្រា ១០៤០ កថាខ័ណ្ឌទី១) តាមរយៈការពិភាក្សាគ្នាអំពីរបៀបក្នុការចូលជួបកូនដោយកំណត់អំពីពេលវេលា និងការបរិច្ឆេទដែលត្រូវចូលជួបអោយ

ច្បាស់លាស់ ឬអោយមានការជូនដំណឹងជាមុនសម្រាប់អោយអ្នកមានអំណាចមេបារៀបចំសម្រួលកិច្ចការនេះ ចៀសវាងការប៉ះពាល់ដល់ពេលវេលាសិក្សារបស់កូនផងដែរ(មាត្រា១០៤០ កថាខ័ណ្ឌទី២)។ ប៉ុន្តែ បើការពិភាក្សាគ្នានេះ ពុំបានសម្រេច ឬពុំអាចធ្វើទៅបានទេ តុលាការជាអ្នកកំណត់អំពីការចូលជួបប្រាស្រ័យទាក់ទង ដោយយកផលប្រយោជន៍កូនជាអាទិភាព និងតម្រូវកំណត់អំពីសោហ៊ុយចាំបាច់ ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬម្តាយដែលទាមទារអំណាចមេបានោះអវត្តមាន ឬមានជំងឺ ឬមានធុរៈ មិនអាចទាមទារទៅតុលាការបានទេ ញាតិនៅក្នុង ៤(បួន) ថ្នាក់របស់កូនអាចធ្វើការទាមទារ ដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី៤ និង ៥ នៃមាត្រា ១០៤០បាន។

ម្យ៉ាងវិញទៀត ឪពុក ឬម្តាយ ដែលពុំមានអំណាចមេបាលើកូន ក៏មានសិទ្ធិអាចទាមទារអោយអ្នកដែលមានអំណាចមេបារាយការណ៍អំពីស្ថានភាពរបស់កូននោះបាន តាមរយៈការពិភាក្សាព្រមព្រៀងរវាងឪពុក/ម្តាយចំពោះខ្លឹមសារនោះ។ ប៉ុន្តែ បើការពិភាក្សាពុំមានលទ្ធផល ឬពុំអាចធ្វើទៅបាន តុលាការអាចសម្រេចសេចក្តីជំនួសបាន។ ចំណែង ញាតិ ៤(បួន) ថ្នាក់របស់កូន ក៏មានសិទ្ធិអាចទាមទារចំពោះករណីនេះបានដែរ (មាត្រា ១០៤១)។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើមកនេះ យើងមើលឃើញថា វិធីសាស្ត្រដ៏ល្អក្នុងការបញ្ចប់ទំនាក់ទំនងអាពាហ៍ពិពាហ៍នេះ គឺការដោះស្រាយតាមប្រព័ន្ធតុលាការដោយអនុលោមទៅតាមច្បាប់ដែលកំណត់នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។ ហើយបានកំណត់អំពីការបែងចែកទ្រព្យ និងអំណាចមេបាលើកូនដែលច្បាប់នេះមានលក្ខណៈចាប់បង្ខំអោយភាគីនីមួយៗត្រូវតែប្រតិបត្តិ។ បុគ្គលម្នាក់ៗ ដែលជានីតិជនត្រូវតែធ្វើការសម្រេចចិត្តអោយបានត្រឹមត្រូវ មុននឹងរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនរណាម្នាក់ស្របតាមប្រពៃណីទំនៀមទម្លាប់ខ្មែរ និងតាមផ្លូវច្បាប់។ ដើម្បីចៀសវាកុំអោយកើតមានករណីនៃការលែងលះ ប្តី ឬប្រពន្ធ ត្រូវតែចេះអត់ឱនអោយគ្នាទៅវិញទៅមក ទើបគ្រួសារមានសុភមង្គល ពីព្រោះការលែងលះធ្វើអោយខូចខាតប្រយោជន៍ជាច្រើនទាំងពេលវេលា និងប្រាក់កាស ហើយជាពិសេសប៉ះពាល់ដល់សតិអារម្មណ៍ថែមទៀតផង។

ការបង្កើតក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី គឺបានផ្តល់ប្រយោជន៍ជាច្រើន ដើម្បីងាយស្រួលដោះស្រាយ និងការពារភាពសុចរិតយុត្តិធម៌នូវរាល់វិវាទកើតមានឡើងនៅក្នុងសង្គម រវាងភាគីប្តីប្រពន្ធ ដែលចង់រំលាយចំណងអាពាហ៍ពិពាហ៍ ព្រោះថា ច្បាប់មានលក្ខណៈចាប់បង្ខំអោយភាគីទាំងពីរត្រូវតែគោរព គ្មាននរណាម្នាក់ដែលថាមិនគោរពឡើយ។

ដើម្បីជ្រើសរើសដៃគូប្រចាំជីវិត បុគ្គលម្នាក់ៗត្រូវតែសិក្សាស្វែងយល់អំពីចិត្តគ្នាទៅវិញទៅមកសិន មុននឹងសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយនរណាម្នាក់ប្រកបដោយសុភមង្គលនៅក្នុងគ្រួសារ ។ ដោយហេតុថា ការមិនយល់ចិត្ត មិនចុះសម្រុងគ្នា ធ្វើអោយកើតមាននូវអំពើហិង្សា និងជម្លោះក្នុងគ្រួសារឈានដល់ការលែងលះ៕

# ឯកសារយោង


**១.** ក្រសួងយុត្តិធម៌ “ក្រមរដ្ឋប្បវេណី”  បោះពុម្ពលើទី១.......................................................ឆ្នាំ២០០៧

**២.** ក្រសួងយុត្តិធម៌ “ក្រមនីតិវិធីរដ្ឋប្បវេណី”  បោះពុម្ពលើទី១.............................................ឆ្នាំ២០០៦

**៣.** ច្បាប់ស្ដីពី “អាពាហ៍ពិពាហ៍ និងគ្រួសារ”..................................អនុម័តថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩